Unofficial translation

# សេចក្តីប្រកាសព័ត៌មាន

## អ្នកជំនាញការសហប្រជាជាតិ សំដែងនូវការព្រួយបារម្ភចំពោះការដាក់កំហិតសេរីភាពមេធាវីការពារកូនក្តីរបស់ខ្លួន

ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩

**ទីក្រុងហ្សឺណែវ**-លោកឡេអង់ដ្រូ ដេសពុយ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិពីឯករាជភាពចៅក្រម និងមេធាវី បានសំដែងនូវការព្រួយបារម្ភរបស់លោក នៅថ្ងៃនេះចំពោះការប៉ុនប៉ងថ្មីៗ ដើម្បីដាក់កំហិតសេរីភាពមេធាវី ការពារកូនក្តីរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពនៅកម្ពុជា។

លោកដេសពុយបានថ្លែងថា"ដើម្បីអាចការពារកូនក្តីរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព មេធាវីមិនត្រូវស្ថិតក្រោមការគំរាមកំហែង ឬការបំភិតបំភ័យឡើយ ហើយមេធាវី ក៏មិនត្រូវជាគោលដៅសំរាប់ការចោទប្រកាន់ ឬទណ្ឌកម្មខាងវិន័យ ដោយសារតែបានធ្វើការងារ ដើម្បីជាប្រយោជន៍ដល់កូនក្តីរបស់ខ្លួននោះទេ។" លោកបានបន្ថែមទៀតថា "មេធាវីមានតួនាទីសំខាន់ជាអ្នកការពារសិទ្ធិមនុស្ស ហើយត្រូវតែមានសេរីភាពការពារកូនក្តីរបស់ខ្លួន តាមតែខ្លួនមើលឃើញថា សក្តិសម ស្របតាមនិយាមការវិជ្ជាជីវៈ និងវិធាននៃច្បាប់។ ដោយបានធ្វើការតាមដានយ៉ាងយកចិត្តទុកដាក់ ចំពោះស្ថានភាពនៅកម្ពុជា ពេញអាណត្តិរបស់លោក អ្នករាយការណ៍ពិសេសព្រួយបារម្ភថា "ចរន្តថ្មីៗនេះនៅកម្ពុជាប្រឆាំងនឹងមេធាវី ហាក់ដូចជាបង្ហាញពីនិន្នាការព្រួយបារម្ភថ្មីដែលអាចបង្កឲ្យមានឥទ្ធិពលភ័យខ្លាចដល់វិជ្ជាជីវៈច្បាប់។" លោកបានបន្តថា "ខ្ញុំសូមគាំទ្រ និងលើកទឹកចិត្តក្រុមប្រឹក្សា និងប្រធានគណៈមេធាវីពីកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីពង្រឹងវិជ្ជាជីវៈច្បាប់នៅកម្ពុជា និងដើម្បីការពារមេធាវីចំពោះការប៉ុនប៉ងធ្វើឲ្យខូចខាតដល់ឯករាជភាពគណៈមេធាវី។"

កាលពីសប្តាហ៍មុន មេធាវីម្នាក់ ដែលការពារក្តីឲ្យសមាជិកសភា គណៈបក្សប្រឆាំង ដែលបានចោទប្រកាន់ថា លោកនាយករដ្ឋមន្ត្រីបានបរិហារកេរ្តិ៍លោកជំទាវនោះ ត្រូវបានទទួលការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ហើយប្រឈមមុខនឹងការគំរាមកំហែងពីការបណ្តេញចេញពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ កាលពីខែមករា ឆ្នាំ២០០៩ មេធាវីការពារក្តីដែលធ្វើជាស្មាក្តី នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានគំរាមកំហែង ដោយចៅក្រមកម្ពុជា តាមការចាត់ការតាមផ្លូវច្បាប់ដែលអាចធ្វើទៅបាន ចំពោះការបានអំពាវនាវឲ្យមានការស៊ើបអង្កេតឲ្យបានត្រឹមត្រូវ ពីការចោទប្រកាន់អំពើពុករលួយ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញនេះ ដោយសាលាដំបូងក្រុងភ្នំពេញ។ មុននេះបន្តិច កាលពីខែមិថុនា ឆ្នាំ២០០៧ មេធាវីដែលការពារក្តីឲ្យសហគមន៍ជនជាតិដើមភាគតិច នៅក្នុងខេត្តរតនគិរី ក្នុងរឿងវិវាទដីធ្លី

ជាមួយនឹងលោកជំទាវជាពាណិជ្ជករម្នាក់ ដែលមានទំនាក់ទំនងយ៉ាងជិតស្និត ជាមួយរដ្ឋាភិបាល ក៏ត្រូវបានទទួលរងការគំរាមកំហែង ពីការចោទប្រកាន់ ពីបទព្រហ្មទណ្ឌ និងទណ្ឌកម្មខាងវិន័យ នៅចំពោះមុខក្រុមប្រឹក្សាគណៈមេធាវីដែរ ពីការចោទប្រកាន់ថា "បានញុះញង់" សហគមន៍ឲ្យដាក់ពាក្យបណ្ដឹងទាមទារយកដីសហគមន៍របស់ពួកគាត់វិញ។

អ្នករាយការណ៍ពិសេស សូមធ្វើការរំលឹកដល់រាជរដ្ឋាភិបាលកម្ពុជា ពីកាតព្វកិច្ចរបស់ខ្លួនក្រោមច្បាប់អន្តរជាតិ ដូចដែលមានចែងនៅក្នុង **គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីតួនាទីរបស់មេធាវី** ដែលបញ្ជាក់យ៉ាងច្បាស់ថា "មេធាវីមិនត្រូវក្លាយជាមុខសញ្ញាជាមួយកូនក្ដីរបស់ខ្លួន ឬជាមួយបុព្វហេតុកូនក្ដីរបស់ខ្លួន ដោយសារតែការបំពេញតួនាទីរបស់ខ្លួន ឲ្យកូនក្ដីនោះឡើយ។" គោលការណ៍ទាំងនោះបន្តទៀតថា "រដ្ឋាភិបាលត្រូវធានាថា មេធាវីអាចបំពេញមុខងារវិជ្ជាជីវៈទាំងអស់របស់ខ្លួន ដោយគ្មានការបំភិតបំភ័យ ការបន្ទុចបង្អាក់ ការយាយី ឬការជ្រៀតជ្រែកដែលមិនត្រឹមត្រូវឡើយ ហើយមិនត្រូវទទួលរង ឬត្រូវបានគំរាមកំហែង ដោយការចោទប្រកាន់តាមផ្លូវតុលាការ ឬរដ្ឋបាល ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ឬទណ្ឌកម្មឯទៀត ចំពោះសកម្មភាពណាមួយដែលខ្លួនបានធ្វើ ស្របតាមបទដ្ឋាន តួនាទី និងបញ្ញត្តិក្រមសីលធម៌វិជ្ជាជីវៈ ដែលត្រូវបានទទួលស្គាល់ឡើយ។" លើសពីនេះទៅទៀត មេធាវីគួរទទួលបានអភ័យឯកសិទ្ធិផុតពីបណ្ដឹងរដ្ឋប្បវេណី ឬព្រហ្មទណ្ឌ ចំពោះការធ្វើសេចក្ដីថ្លែងដោយសុទ្ធចិត្ត ពាក់ព័ន្ធនឹងការលើកអំណះអំណាងការពារកូនក្ដី ទោះជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ក្ដី ឬនៅក្នុងការបង្ហាញខ្លួនជាវិជ្ជាជីវៈរបស់ខ្លួន នៅចំពោះមុខតុលាការ សាលាក្ដី ឬអាជ្ញាធរច្បាប់ ឬរដ្ឋបាលដទៃទៀត។

អ្នករាយការណ៍ពិសេស ក៏បានអំពាវនាវផងដែរថា ទុកឲ្យក្រុមប្រឹក្សាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាចបំពេញការទទួលខុសត្រូវរបស់ខ្លួន តាមច្បាប់លក្ខន្តិកៈមេធាវី ដោយគ្មានសម្ពាធពីខាងក្រៅ ដើម្បីការពារឯករាជភាព និងស្វ័យភាព នៃវិជ្ជាជីវៈច្បាប់ នៅកម្ពុជា ។

៙៙៙*៚៚

**<u>សំគាល់:</u>** សេចក្ដីប្រកាសព័ត៌មាននេះចេញដោយលោកឡេអង់ដ្រូដេសពុយ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ពីឯករាជភាពចៅក្រម និងមេធាវី ។ លោកដេសពុយ មានអាណត្តិខុសគ្នាដាច់ស្រឡះពី អ្នករាយការណ៍ពិសេសទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា គឺលោកសាស្ត្រាចារ្យសូរិយា ស៊ុបេឌី។